

# ផ្ទះផ្សេងៗគ្នា

Komar Rien Komar Cheh

Meth Phearum

Let's Read
The Asia Foundation



ផ្ទះខ្ញុំធ្វើអំពីឫស្សី។ ផ្ទះខ្ញុំនៅទីខ្ពស់ជិតដើមឈើ។



ផ្ទះខ្ញុំធ្វើអំពីឈើនៅផ្ទាល់ដី។ ពុកម៉ែលក់ទំនិញចាប់ហួយនៅផ្ទះយើង។



ផ្ទះខ្ញុំធ្វើអំពីឈើ ប្រក់ក្បឿង។ ខ្ញុំតែងតែលេងនៅក្រោមផ្ទះ។



ផ្ទះខ្ញុំធ្វើអំពីថ្ម នៅផ្ទាល់ដី។ មីងរបស់ខ្ញុំលក់ផ្លែឈើនៅផ្ទះខ្ញុំ។



ផ្ទះខ្ញុំធ្វើអំពីថ្មដែរ តែវានៅជាន់ទី១។ អ៊ំខ្ញុំបើកហាងកាត់ដេរ
ខោអាវនៅផ្ទះរបស់ខ្ញុំ។



ផ្ទះខ្ញុំធ្វើអំពីឈើនៅខាងលើ និងថ្មនៅខាងក្រោម។ បងប្រុសខ្ញុំបើកជួសជុលម៉ូតូនៅខាងក្រោមផ្ទះ។



ផ្ទះខ្ញុំធ្វើអំពីឈើនៅលើទឹក។ យើងអាចចាប់ត្រីបានច្រើន។



ប្រទេសយើងមានផ្ទះផ្សេងៗគ្នា។ តើផ្ទះរបស់កូនមានរូបរាង
យ៉ាងដូចម្តេច?



## សំណួរ

១. តើផ្ទះប្រភេទណាដែលនៅទីខ្ពស់ជិតដើមឈើ?

២. តើគេបើកហាងកាត់ដេរខោអាវនៅផ្ទះប្រភេទណា?

៣. តើកូនគិតថា ផ្ទះនៅលើទឹកសង់អំពីអ្វី?

៤. តើផ្ទះរបស់កូនសង់អំពីអ្វី? មានរូបរាងយ៉ាងដូចម្ដេច?

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**

*ផ្ទះផ្សេងៗគ្នា (Different Houses)*, Author: Komar Rien Komar Cheh. Illustrator: Meth Phearum. Published by The Asia Foundation - Let's Read, © The Asia Foundation - Let's Read. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2020. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by/4.0/